**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល
លេខ ០៥៤......ក.ប.ល-ម៧

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០១១

## សារាចរណែនាំ

## ស្តីពី

## ការកំណត់តម្លៃព្យាបាលជំងឺ នៅតាមសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន

រយៈកាលកន្លងមក ក្រសួងសុខាភិបាលបានសង្កេតឃើញថា មន្ទីរសម្រាកព្យាបាល និងមន្ទីរពហុព្យាបាលឯកជនមួយចំនួនបានកំណត់តារាងតម្លៃសេវាព្យាបាលឱ្យអ្នកជំងឺបានដឹងមុន ដើម្បីធ្វើការសម្រេចចិត្ត។ ប៉ុន្តែមានកន្លែងព្យាបាលជំងឺឯកជនមួយចំនួនទៀតពុំបានកំណត់អំពីតម្លៃសេវាព្យាបាលជំងឺរបស់ខ្លួនឱ្យអ្នកជំងឺបានដឹងជាមុនទេ ពេលខ្លះបានយកតម្លៃសេវាព្យាបាលច្រើនលើសលុប ដែលធ្វើឱ្យមានផលប៉ះពាល់ទៅដល់សតិអារម្មណ៍របស់អ្នកជំងឺ ជាពិសេសលទ្ធភាពក្នុងការបង់ថ្លៃរបស់គាត់។

ដើម្បីជៀសវាងផលប៉ះពាល់ទាំងនេះ ក្រសួងសុខាភិបាលសូមធ្វើការណែនាំដល់ម្ចាស់សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជនទាំងអស់អនុវត្តតាមសេចក្តីណែនាំដូចខាងក្រោមនេះ :

១-ត្រូវសរសេរតារាងតម្លៃសេវាព្យាបាលជំងឺឱ្យបានត្រឹមត្រូវ និងពិតប្រាកដ ផ្ញើរមកឱ្យនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល ។

២-តារាងតម្លៃសេវាព្យាបាលជំងឺខាងលើនេះ ត្រូវសរសេរជាផ្ទាំងធំភ្ជាប់នៅលើជញ្ជាំងកន្លែងបន្ទប់រង់ចាំ ងាយស្រួលឱ្យសាធារណជន និងអ្នកជំងឺមើលឃើញ និងដឹងជាមុន មុននឹងសម្រេចចិត្តទទួលយកសេវាព្យាបាល។

ទទួលបានសារាចរនេះ នាយកដ្ឋានមន្ទីរពេទ្យ មន្ទីរសុខាភិបាលរាជធានី-ខេត្ត គ្រប់ម្ចាស់សេវាព្យាបាលជំងឺឯកជនទាំងអស់ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

ជ.រដ្ឋមន្ត្រីក្រសួងសុខាភិបាល
រដ្ឋលេខាធិការ

សាស្ត្រាចារ្យ ហេង តៃគ្រី

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- នាយកដ្ឋានមន្ទីរពេទ្យ (ដើម្បីអនុវត្ត)
- មន្ទីរសុខាភិបាលរាជធានី-ខេត្ត (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ